**និយ័តករបរធនបាលកិច្ច**

**TRUST REGULATOR**

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងគោលការណ៍ណែនាំស្តីពី “បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច”

ថ្ងៃសុក្រ ១២កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៣

ទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

នាព្រឹកថ្ងៃសុក្រ ១២កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៣ **និយ័តករបរធនបាលកិច្ច** (**ន.ប.ធ.**) បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងគោលការណ៍ណែនាំស្តីពី **“បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច”** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយឯកឧត្តមអគ្គនាយករង ប្រធាននាយកដ្ឋាន និងសហការីនៃ **ន.ប.ធ.** ដោយមានការចូលរួមដោយផ្ទាល់មកពី÷ (១).តំណាងពីអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល, (២).តំណាងពីមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី “តេជោ”, (៣).តំណាងពីនិយ័តករ និងអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) រួមមាន តំណាងពីនិយ័តករមូលបត្រកម្ពុជា, តំណាងពីនិយ័តករធានារ៉ាប់រងកម្ពុជា, តំណាងពីនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ, តំណាងពីនិយ័តករសន្តិសុខសង្គម, តំណាងពីនិយ័តករគណនេយ្យនិងសវនកម្ម, តំណាងពីអង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** និងតំណាងពីអគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** និង (៤).តំណាងមកពីបរធនបាល, ក្រុមបរធនបាលនៃបរធនបាលកិច្ចហិរញ្ញវត្ថុ, បុគ្គលថែរក្សាសុវត្ថិភាពបរធន, បុគ្គលថែរក្សាទ្រព្យសម្បត្តិជំនួស, បុគ្គលផ្តល់សេវាពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច និងបុគ្គលពាក់ព័ន្ធផ្សេងទៀត នៅទីស្តីការ **អ.ស.ហ.**។

គោលបំណងនៃកិច្ចប្រជុំនេះ គឺដើម្បីទទួលបានមតិយោបល់ និងធាតុចូលបន្ថែមពីតួអង្គ និងភាគីពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច ដើម្បីឱ្យការរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំនេះកាន់តែមានលក្ខណៈពេញលេញ និងគ្រប់ជ្រុងជ្រោយ ដែលសំដៅដល់ការអនុវត្តប្រកបដោយសណ្តាប់ធ្នាប់ តម្លាភាព ប្រសិទ្ធភាព និងទំនុកចិត្តពីអ្នកចូលរួមក្នុងវិស័យបរធនបាលកិច្ច។